fact sheet

Khmer
November 2003
[AHS-7295]

# រោគលឿងចំពោះទារកទើបកើត

## Jaundice in newborn babies

សេចក្តីប្រកាសមិនទទួលខុសត្រូវ:
ប័ណ្ណព័ត៌មាននេះគឺសំរាប់ការអប់រំតែប៉ុណ្ណោះ។ សូមពិគ្រោះយោបល់ជាមួយវេជ្ជបណ្ឌិតលោកអ្នក ឬក៏អ្នកមានវិជ្ជាជីវៈផ្នែកសុខភាព ដើម្បីឲ្យច្បាស់ថា ព័ត៌មានេះពិតជាត្រឹមត្រូវចំពោះកូនលោកអ្នក។

ជំងឺលឿងចំពោះទារកទើបកើតគឺធ្វើឲ្យស្បែកឡើងពណ៌លឿង ហើយភ្នែកឡើងពណ៌ស។ រោគលឿងដែល មើលទៅឃើញជាក់ស្តែង កើតឡើងចំពោះទារកទើបកើតរួច ចំនួនមួយភាគបី ឬក៏ចំនួនពាក់កណ្តាល នៃទារកធម្មតាដែលទើបកើត។ តាមធម្មតា ជំងឺនេះមិនបង្កឲ្យមានបញ្ហាអ្វីឡើយ ហើយជាទូទៅរសាយបាត់ទៅវិញ បន្ទាប់ពីទារកមានអាយុមួយអាទិត្យ។ បើសិនជារោគលឿងនេះមិនរសាយបាត់ទៅវិញ ក្រោយពីពេលមួយអាទិត្យទេ ឬក៏នៅតែបន្តវត្តមានតទៅទៀត ក្រោយពីពេល២អាទិត្យនោះ សូមទាក់ទងវេជ្ជបណ្ឌិតលោកអ្នក ឬក៏មន្ទីរពេទ្យតាមមូលដ្ឋាន។

### តើអ្វីទៅដែលបង្កឲ្យស្បែកឡើងពណ៌លឿងនោះ?

នៅក្នុងរាងកាយមនុស្សលោកយើង ឈាមថ្មីត្រូវកើតឡើងគ្រប់ពេលទាំងអស់ ហើយឈាមចាស់ត្រូវតែអស់ជីវិត។ សារធាតុមួយក្នុងចំណោមសារធាតុឈាមដែលងាប់ទាំងនោះ មានឈ្មោះថា ប៊ីលីរូប៊ីន (bilirubin) ។ ប៊ីលីរូប៊ីននេះ តាមធម្មតាធ្វើដំណើរទៅថ្លើម ហើយចេញពីរាងកាយតាមរយៈលាមក។  ចំពោះ២-៣ថ្ងៃដំបូងក្រោយពីប្រសូតរួច ថ្លើមរបស់ទារកមិនទាន់ដើរស្រួលល្អឡើយ។ ដូច្នេះសារធាតុប៊ីលីរូប៊ីនអាចប្រមូលផ្តុំនៅក្នុងឈាម។ កត្តានេះហើយដែលធ្វើឲ្យស្បែកឡើងពណ៌លឿង ហើយភ្នែកឡើងពណ៌សនោះ។

### តើរោគលឿងមានគ្រោះថ្នាក់ឬទេ?

បើសិនជាប៊ីលីរូប៊ីនមានកំរិតខ្ពស់ពេក សារធាតុនេះអាចធ្វើឲ្យទារកងោកងុយ។ កំរិតប៊ីលីរូប៊ីនច្រើនពេកអាចនាំឲ្យមានបញ្ហាសោតវិញ្ញាណនិងការខូចខួរក្បាល។  នៅក្នុងមន្ទីរពេទ្យ គេយកចិត្តទុកដាក់មិនឲ្យកំរិតប៊ីលីរូប៊ីនឡើងខ្ពស់ខ្លាំងឡើយ។ រោគលឿងក៏អាចបង្កឡើងដោយជំងឺថ្លើមដែរ។ ហេតុដូច្នេះហើយបានជាការទាក់ទងវេជ្ជបណ្ឌិត របស់លោកអ្នកគឺជារឿងសំខាន់។ សញ្ញាមួយក្នុងចំណោមសញ្ញានៃជំងឺថ្លើម គឺនៅពេលដែលលាមករបស់ទារកមានពណ៌សជាងលាមកធម្មតា ដែលទូទៅគឺមានពណ៌លឿងចាស់។

### តើទារកណាខ្លះដែលមានរោគលឿងកំរិតខ្លាំងនោះ?

ទារកដែលទំនងជានឹងកើតរោគលឿង រួមមាន:

- ទារកកើតមិនគ្រប់ខែ
- ទារកមានរោគ

- ប្រភេទឈាម ឬក៏ RH របស់ទារក - ទារកទាំងឡាយណាដែលមានប្រភេទក្រុមឈាមមួយខុសពីឈាមម្ដាយរបស់ខ្លួន។ អាស្រ័យហេតុនេះហើយ ទើបមានប្រតិកម្មដែលបំផ្លាញកោសិកាឈាមរបស់ទារកយ៉ាងឆាប់រហ័សជាងធម្មតា។

## ការវាស់ស្ទង់កំរិតនៃរោគលឿងដែលឃាយឃីទារក

ការធ្វើតេស្ដឈាមគឺជាការឆែកមើលកំរិតប៊ីលីរូប៊ីន។ មន្ទីរពេទ្យខ្លះក៏ប្រើឧបករណ៍មួយដាក់នៅលើស្បែកទារកដែលជាការឆែកពិនិត្យមួយ ដើម្បីជាជំនួយក្នុងការសំរេច ថាតើគេត្រូវធ្វើតេស្ដឈាមឬអត់។ បុគ្គលិកពេទ្យនឹងធ្វើតេស្ដឈាមទារក បើសិនជា:

- មានកត្តាដែលអាចនាំឲ្យមានគ្រោះថ្នាក់ មានដូចជា ការកើតមិនគ្រប់ខែ
- រោគលឿងកើតឡើង នៅក្នុងអម្លុងពេល២-៣ថ្ងៃដំបូងក្រោយពីទារកប្រសូតរួច

## ការព្យាបាល

ការទទួលជាតិទឹកឲ្យបានគ្រប់គ្រាន់គឺមានសារសំខាន់សំរាប់ទារកទើបកើត។ រោគលឿងជាទូទៅមានសភាពយ៉ាប់យ៉ឺនឡើង ដោយសារកង្វះជាតិទឹកបង្គួរ។ ការមានរោគលឿងស្រាលនៅក្នុងអាទិត្យទីមួយ មិនត្រូវការការព្យាបាលឡើយ តែត្រូវការជាតិទឹក។ គេព្យាបាលរោគលឿងខ្លាំងបង្គួរ ដោយការដាក់ទារកដែលមានខ្លួនទទេ (ដោយមានពាក់ម៉ាសការពារភ្នែក) នៅក្រោមពន្លឺភ្លើងភ្លឺមួយ ឬក៏ភ្លើងដែលមានពន្លឺពណ៌រាងខៀវ។ គេហៅដំណើរការនេះថា ការព្យាបាលដោយពន្លឺភ្លើង។

ពន្លឺភ្លើងនេះបំបែកនូវសារធាតុប៊ីលីរូប៊ីន នៅក្នុងស្បែក ហើយធ្វើឲ្យស្បែកលឿងនោះរសាយ។ ការព្យាបាលដោយពន្លឺភ្លើងនេះអាចធ្វើឲ្យទារកមានការរាករូសបន្ដិច។ គេអាចដោះស្រាយបញ្ហានេះបាន ដោយការផ្ដល់ជាតិទឹក ទៅទារកឲ្យបានច្រើនជាងមុន។ ការដាក់ទារកនៅក្រោមពន្លឺថ្ងៃដោយផ្ទាល់ ដោយគ្មានកាត្រួតពិនិត្យ អាចនាំគ្រោះដល់ទារក ដោយធ្វើឲ្យទារករលាក។ នៅក្នុងលក្ខណៈដែលមានរោគលឿងធ្ងន់ធ្ងរ ទារកអាចត្រូវការការបញ្ចូលឈាមពិសេសមួយ ក្នុងគោលបំណងប្ដូរយកឈាមថ្មី ដើម្បីលាងជំរុះសារធាតុប៊ីលីរូប៊ីនចេញពីប្រព័ន្ធ។

## តើមានបញ្ហារយៈពេលយូរ ដោយសាររោគលឿងនេះឬទេ?

តាមធម្មតា ក្រោយពីទារកមានរោគលឿងរួច គេគ្មានបញ្ហារយៈពេលយូរឡើយ។ ទារកដែលមានរោគលឿងកំរិតខ្ពស់ គួរតែឲ្យពេទ្យឆែកពិនិត្យមើលសោតវិញ្ញាណ ទៅតាមចន្លោះពេលឲ្យបានទៀងទាត់។ លោកអ្នកគប្បីពិភាក្សាបញ្ហានេះ ជាមួយនឹងវេជ្ជបណ្ឌិត ឬក៏គិលានុបដ្ឋាកផ្នែកថែទាំកុមាររបស់លោកអ្នក។ ការខូចខួរក្បាលបង្កឡើងដោយរោគលឿងកំរិតខ្ពស់ ឥឡូវនេះកំរកើតមានឡើងណាស់ ដោយសារមានការឃ្លាំពិនិត្យមើលកំរិតសារធាតុប៊ីលីរូប៊ីនយ៉ាងប្រុងប្រយ័ត្ន នៅក្នុងអម្លុងពេល២-៣ថ្ងៃដំបូង ក្រោយពេលទារកប្រសូតរួចនៅក្នុងមន្ទីរពេទ្យ ឬក៏នៅតាមគេហដ្ឋានតាមរយៈកម្មវិធីឲ្យចេញពីមន្ទីរពេទ្យឲ្យបានឆាប់។

## សូមចងចាំថា:

- បើសិនជារោគលឿងមិនចាប់ផ្ដើមរសាយក្រោយពីពេលមួយអាទិត្យទេនោះ ឬក៏នៅតែកើតមានក្រោយពេល២អាទិត្យនោះ សូមទាក់ទងវេជ្ជបណ្ឌិតរបស់លោកអ្នកឬក៏មន្ទីរពេទ្យតាមមូលដ្ឋាន។

- រោគលឿងអាចបណ្ដាលមកពីកត្តាផ្សេងៗទៀត មានដូចជាជំងឺថ្លើមជាដើម។ ហេតុដូច្នេះហើយ ការទាក់ទងវេជ្ជបណ្ឌិតរបស់លោកអ្នកតាមមូលដ្ឋាន គឺជាការសំខាន់ បើសិនជារោគលឿងមិនរសាយបាត់ទេនោះ។


The Children's Hospital at Westmead
Tel: (02) 9845 3585
Fax: (02) 9845 3562
http://www.chw.edu.au/

Sydney Children's Hospital, Randwick
Tel: (02) 9382 1688
Fax: (02) 9382 1451
http://www.sch.edu.au/


© The Children's Hospital at Westmead & Sydney Children's Hospital, Randwick - 1997-2004

This document was reviewed on Wednesday, 5 November 2003.